**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ: | សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | បារាំង/ភាសាខ្មែរ |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ |

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Aug-2013, 12:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ និងមានឧបសម្ព័ន្ធសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈរបស់ អង្គជំនុំជម្រះសាលាដំបូង (E218/7/2) ទាក់ទងទៅនឹងគម្រោងសំណងសម្រាប់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០១ និងមានឧបសម្ព័ន្ធសម្ងាត់**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

គង់ ផល្លះ

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Jeanne SULZER
Philippine SUTZ
Beini YE

<u>**ផ្ញើជូន**</u>**៖**

<u>**ការិយាល័យសហព្រះរាជអាជ្ញា**</u>**៖**

ជា លាង

Andrew T. CAYLEY

យ៉េត ចរិយា

William SMITH

<u>**ជនជាប់ចោទ**</u>**៖**

ខៀវ សំផន

នួន ជា

<u>**សហមេធាវីការពារក្តី**</u>**៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

## I. វិញ្ញាសាលីតិវិធី

១. នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ជាបឋមអំពីខ្លឹមសារជាក់លាក់នៃសំណង ដែលខ្លួនមានបំណងស្នើសុំ នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង។ ដោយសារអង្គជំនុំជម្រះបានស្នើឱ្យបង្ហាញលំអិតជាងនេះ[1] សហមេធាវីនាំមុខក៏បានបង្ហាញខ្លឹមសារនៃគម្រោងម្តងទៀត នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១[2]។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះបានស្នើឱ្យសហមេធាវីនាំមុខផ្តល់បញ្ជីគម្រោងអាទិភាព និងព័ត៌មានបន្ថែមមួយចំនួនទៀត[3]។ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ សហមេធាវីនាំមុខ បានដាក់សារណា ដោយបង្ហាញបញ្ជីបណ្តោះអាសន្ននៃគម្រោងអាទិភាព និងព័ត៌មានបន្ថែមមួយចំនួន ដូចជា ស្ថានភាពនៃការផ្តល់ហិរញ្ញប្បទានដល់គម្រោងទាំងនេះនៅដំណាក់កាលនោះ[4]។

២. នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានផ្ញើអនុស្សរណៈមួយ ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីស្នើសុំព័ត៌មានបន្ថែមអំពីប្រភេទនីមួយៗនៃគម្រោង និងគម្រោងនីមួយៗ[5]។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរអំពីកាលវិភាគ សម្រាប់ផ្តល់ព័ត៌មានមួយចំនួន ឱ្យបានមុនថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ។

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង៖ “ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន (៣) នៃវិធានផ្ទៃក្នុង” ឯកសារ E125 ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១។

[2] ប្រតិចារឹកសវនាការស្តីពីការស្នើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E1/11.1 ចុះថ្ងៃ ១១ ខែ មករា ឆ្នាំ ២០១២ ទំព័រ ៦-៤៨។

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង៖ “ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន (៤) នៃវិធានផ្ទៃក្នុង)” ឯកសារ E218/7 ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១១។

[4] ការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខជូនដល់អង្គជំនុំជម្រះសាលាដំបូង អំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន (៤)) ឯកសារ E218/7/1 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[5] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីគម្រោងអាទិភាពសម្រាប់ការអនុវត្តសំណង អនុលោមតាមវិធាន ៨០ ស្ទួន (៤) (E218/7/1) ឯកសារ E218/7/2។

៣. តាមរយៈសារណានេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមឆ្លើយតបទៅនឹងសំណើសុំព័ត៌មានបន្ថែមរបស់អង្គជំនុំជម្រះ។ សហមេធាវីនាំមុខសូមបញ្ជាក់ថា សហមេធាវីនាំមុខបានបន្ថែមគម្រោងថ្មីទៅនឹងគម្រោងប្រាំពីរដំបូង ហើយមកទល់នឹងថ្ងៃនេះ គម្រោងទាំងនេះគ្មានឧបសគ្គអ្វីរាំងមិនឲ្យអនុវត្តបានទេ។ ទោះជាយ៉ាងណាក៏ដោយ មានតែអង្គជំនុំជម្រះប៉ុណ្ណោះដែលមានយុត្តាធិការក្នុងការវាយតម្លៃលើករណីនេះ នៅក្នុងសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន។

## II. ចម្លើយជូនអង្គជំនុំជម្រះ

នៅក្នុងប្រភេទទីមួយ "**ការរំឭក និងការគោរពវិញ្ញាណក្ខ័ន្ធ**"៖

៤. នៅក្នុងប្រភេទនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចបង្ហាញគម្រោងជាច្រើនពីក្នុងសេចក្តីបញ្ជាក់ចុងក្រោយជូនអង្គជំនុំជម្រះ ហើយគម្រោងមួយចំនួនជាគម្រោងថ្មី ប៉ុន្តែឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់។

៥. ចំពោះ**ទិវារំឭកការចងចាំ (គម្រោងទី ១)** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ថា ឈរលើគោលជំហររបស់អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ សហមេធាវីនាំមុខត្រូវធានាថា រាជរដ្ឋាភិបាលនឹងគាំទ្រ និងឯកភាពលើគម្រោងនេះ។ បច្ចុប្បន្ននេះ សហមេធាវីនាំមុខ មានលទ្ធភាពអាចដាក់ចូលក្នុងសំណុំរឿងនូវលិខិតរបស់រាជរដ្ឋាភិបាល ផ្ញើជូនសហមេធាវីនាំមុខ តបទៅនឹងលិខិតដែលសហមេធាវីនាំមុខបានផ្ញើជូនរាជរដ្ឋាភិបាល[6]។ លិខិតរបស់រាជរដ្ឋាភិបាលបានគូសបញ្ជាក់យ៉ាងច្បាស់ថា រាជរដ្ឋាភិបាលកំណត់យកថ្ងៃទី២០ ខែឧសភា ជារៀងរាល់ឆ្នាំ ជាទិវាចងចាំ។ រាជរដ្ឋាភិបាលក៏បានបន្ថែមទៀតថា រាជរដ្ឋាភិបាលនឹងចេញអនុក្រឹត្យ ដើម្បីបញ្ជាក់អំពីការសម្រេចនេះ និងបញ្ជាក់អំពីបែបបទក្នុងការអនុវត្ត។ ដូច្នេះ គ្មានឧបសគ្គណាមួយកើតមានឡើង ដែលរាំងអង្គជំនុំជម្រះមិនឲ្យទទួលស្គាល់គម្រោងនេះជាសំណងឡើយ។ សហមេធាវីនាំមុខសូមបន្ថែមទៀតថា ការបង្កើតឱ្យមាន ទិវាចងចាំនេះមិនទាមទារឲ្យមានការផ្តល់ហិរញ្ញប្បទាននោះទេ។

---

[6] សូមមើលឧបសម្ព័ន្ធ ក៖ ចម្លើយរបស់រដ្ឋាភិបាលតបទៅនឹងលិខិតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្ញើជូននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

៦. ចំពោះ**គម្រោងស្តូបសាធារណៈ (គម្រោងទី ២)** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមបញ្ជាក់ថា បូជនីយដ្ឋានមួយចំនួននឹងត្រូវសាងសង់នៅតាមកន្លែងនានា ដែលត្រូវបានជ្រើសរើសក្រោយពីបានពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងអាជ្ញាធរមូលដ្ឋាន ដោយធ្វើការសហការជាមួយអង្គការទទួលបន្ទុកអនុវត្តគម្រោង។ គម្រោងនេះត្រូវបានប្រគល់ជូនអង្គការយុវសន្តិភាព និងអង្គការក្តីករុណា ដែលជាអង្គការមិនមែនរដ្ឋាភិបាលដើម្បីអនុវត្ត ហើយអង្គការទាំងពីរនេះក៏បានបញ្ជាក់ពីការសន្យារបស់ខ្លួនរួចមកហើយដែរ។ គម្រោងនេះ មានរយៈពេល ២៤ខែ ហើយអាចត្រូវបានកាត់បន្ថយក្នុងករណីដែលគ្មានហិរញ្ញប្បទានគ្រប់គ្រាន់ ។ មកទល់នឹងថ្ងៃនេះ មិនទាន់មានការធានាហិរញ្ញប្បទាននៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ លិខិតរបស់រាជរដ្ឋាភិបាលបង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាលនឹងផ្តល់ការណែនាំទៅក្រសួង និងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ចាត់វិធានការចាំបាច់ ដើម្បីសម្រួលដល់ការកំណត់ទីកន្លែងជាក់លាក់ និងការសាងសង់បូជនីយដ្ឋានទាំងនេះ[7]។

៧. គម្រោងមួយទៀត គឺការសាងសង់ **បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ «ជូនចំពោះជនដែលបានបាត់បង់ជីវិត» (គម្រោងទី ៣)** ដោយសិល្បករសញ្ជាតិបារាំង-ខ្មែរ *Séra* ដែលបានបញ្ជាក់ពីការសន្យារបស់ខ្លួនរួចហើយ។ សព្វថ្ងៃនេះ គម្រោងនេះត្រូវបានផ្តល់ហិរញ្ញប្បទានមួយផ្នែក ក្នុងទឹកប្រាក់ចំនួន ៥០.០០០ អឺរ៉ូ ពីសាធារណរដ្ឋបារាំង ដែលជាអ្នកបាននិងកំពុងពិភាក្សាជាមួយនឹងសាលារាជធានីភ្នំពេញ ដើម្បីកំណត់ពីទំហំទីកន្លែងដែលនឹងត្រូវសាងសង់បូជនីយដ្ឋាននោះ[8]។

នៅក្នុងប្រភេទទីពីរ "**ការស្តារនីតិសម្បទា**"៖

៨. ចំពោះ**វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម (គម្រោងទី ៤)** និង**ក្រុមជួយខ្លួនឯង (គម្រោងទី ៥)** អង្គការចិត្តសង្គមអន្តរវប្បធម៌ ទទួលខុសត្រូវក្នុងការអនុវត្ត ហើយបញ្ជាក់ពីការសន្យារបស់ខ្លួនរួចហើយ[9]។ គម្រោងទាំងពីរនេះមានរយៈពេល ៣៦ ខែ ប៉ុន្តែអាចត្រូវបានកាត់បន្ថយក្នុង

---

[7] ដូចគ្នាទៅនឹងជើងទំព័រលេខ ៦

[8] សូមមើលឧបសម្ព័ន្ធ ខ៖ លិខិតរបស់ទូតបារាំងប្រចាំនៅកម្ពុជា ផ្ញើជូនឯកឧត្តម **ក្រាញ់ តុនី**

[9] សូមមើលឧបសម្ព័ន្ធ គ៖ លិខិតសន្យារវាងអង្គការចិត្តសង្គមអន្តរវប្បធម៌ ជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ

ករណីគ្មានហិរញ្ញប្បទានគ្រប់គ្រាន់។ មកទល់នឹងថ្ងៃនេះ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ (BMZ) [10] បានផ្តល់ហិរញ្ញប្បទានមួយផ្នែក ក្នុងទឹកប្រាក់ចំនួន ១២៥.០០០ អឺរ៉ូ[11]។

នៅក្នុងប្រភេទទីបី **"ការចងក្រងឯកសារ និងការអប់រំ"**៖

៩. ចំពោះគម្រោង**តាំងពិព័រណ៍អចិន្ត្រៃយ៍ (គម្រោងទី ៦)** ដែលផ្តោតជាសំខាន់លើការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលខុសត្រូវក្នុងការអនុវត្ត ហើយបានបញ្ជាក់ពីសន្យាជាមួយសហមេធាវីនាំមុខរួចហើយ[12]។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានសន្យាជួយរកហិរញ្ញប្បទានចាំបាច់សម្រាប់អនុវត្តន៍គម្រោង ដែលមានរយៈពេល ៥ឆ្នាំ ហើយនឹងត្រូវអនុវត្តនៅក្នុងសារៈមន្ទីរនៃការចងចាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលស្ថិតនៅក្នុងខេត្តសៀមរាប។ ដូចគ្នានេះដែរ គម្រោងនេះក៏ត្រូវអនុវត្តនៅតាមបណ្តាសារៈមន្ទី សំខាន់ទាំង ២៤ ខេត្ត-ក្រុង ដែលមជ្ឈមណ្ឌលនេះបានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ ដើម្បីធ្វើការតាំងពិពណ៌ពីអ្វីដែលទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យ[13] ។ មកទល់នឹងថ្ងៃនេះ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នៃសហព័ន្ធអាល្លឺម៉ង់ បានផ្តល់ហិរញ្ញប្បទាន ក្នុងទឹកប្រាក់ចំនួន ៨០.០០០ អឺរ៉ូ ដល់គម្រោងមួយផ្នែក សម្រាប់ការតាំងពិព័រណ៍អចិន្ត្រៃយ៍ ចំនួន ៥ នៅតាមបណ្តាសារៈមន្ទីសំខាន់មួយចំនួន ដូចជានៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តតាកែវ ខេត្តស្វាយរៀង និងខេត្តកំពង់ធំ ។

១០. ចំពោះ**គម្រោងតាំងពិព័រណ៍ចល័ត (គម្រោងទី ៧)** ផ្តោតទៅលើសម័យខ្មែរក្រហម ហើយជាពិសេសទៅលើឧក្រិដ្ឋកម្មដែលបាននឹងកំពុងជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ អង្គការយុវសន្តិភាព និងអង្គការក្តីករុណា ទទួលខុសត្រូវក្នុងការអនុវត្តគម្រោងនេះ ហើយបានបញ្ជាក់ពី

---

[10] សូមមើលឧបសម្ព័ន្ធ ឃ៖ លិខិតរបស់អ្នកតំណាងប្រចាំនៅកម្ពុជានៃក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នៃសហព័ន្ធអាល្លឺម៉ង់ ផ្ញើជូន ឯកឧត្តម **ក្លាស់ តូនី**

[11] សូមមើលឧបសម្ព័ន្ធ ឃ៖ លិខិតរបស់អ្នកតំណាងប្រចាំនៅកម្ពុជានៃក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នៃសហព័ន្ធអាល្លឺម៉ង់ ផ្ញើជូន ឯកឧត្តម **ក្លាស់ តូនី**

[12] សូមមើលឧបសម្ព័ន្ធ ង៖ លិខិតសន្យារបស់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

[13] សូមមើលឧបសម្ព័ន្ធ ច៖ លិខិតរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈផ្ញើជូននាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ការសន្យារបស់ខ្លួន ក៏ដូចជារបៀបក្នុងការបែងចែកថវិកា និងការអនុវត្តរួចហើយ។ អង្គការផ្សេងទៀត ដូចជាសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) និងគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) នឹងអាចផ្ដល់ការគាំទ្រជាក់លាក់ ប៉ុន្តែមិនមានសិទ្ធិអំណាចក្នុងការសម្រេចលើការអនុវត្តឡើយ។ រយៈពេលដំបូង គឺ ២៤ ខែ ប៉ុន្តែអាចនឹងកាត់បន្ថយអាស្រ័យទៅតាមហិរញ្ញប្បទានដែលបានផ្ដល់ជូន។ មកទល់នឹងថ្ងៃនេះក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នៃសហព័ន្ធអាល្លឺម៉ង់ បានផ្ដល់ហិរញ្ញប្បទាន ក្នុងទឹកប្រាក់ចំនួន ១០០.០០០ អឺរ៉ូ[14]។

១១. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏មានលទ្ធភាពអាចបង្ហាញគម្រោងតាក់តែង **ជំពូកជាក់លាក់ស្ដីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ (គម្រោងទី ៨)**។ ជំពូកនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងសៀវភៅគរុកោសល្យសម្រាប់គ្រូបង្រៀនដែលបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់បានបោះពុម្ពរួចហើយ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា[15] ។ លិខិតរបស់រដ្ឋាភិបាលបានបញ្ជាក់ផងដែរថា ការបង្រៀនអំពីប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ នឹងត្រូវបានដាក់បញ្ចូលជាផ្លូវការក្នុងកម្មវិធីសិក្សា[16] ។ ដើម្បីធ្វើឱ្យគម្រោងសំណងសម្រេចបាន សៀវភៅនេះនឹងជាកម្មវត្ថុក្នុងការធ្វើបច្ចុប្បន្នភាព និងការបោះពុម្ពថ្មី ដែលនឹងរាប់បញ្ចូលជំពូកថ្មីៗទៀត ។ គម្រោងនេះមានរយៈពេលទាំងអស់ចំនួន ១៥ ខែ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានសន្យាអនុវត្តគម្រោងនេះ[17] ក៏ដូចជាស្វែងរកហិរញ្ញប្បទានសមស្រប។

១២. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមគូសបញ្ជាក់ថា សារណានេះមានគោលបំណងតែមួយគត់ គឺដើម្បីឆ្លើយតបតាមលទ្ធភាពដែលអាចធ្វើទៅបាន នៅក្នុងដំណាក់កាលនេះ

---

[14] សូមមើលឧបសម្ព័ន្ធ ឃ៖ លិខិតរបស់អ្នកតំណាងប្រចាំនៅកម្ពុជានៃក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ ផ្ញើជូន ឯកឧត្តម **គ្រាវញ៉ូ តូនី**

[15] សូមមើលឧបសម្ព័ន្ធ ឆ៖ ឯកសារស្ដីពីសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡាជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

[16] សូមមើលឧបសម្ព័ន្ធ ក៖ ចម្លើយរបស់រដ្ឋាភិបាលតបទៅនឹងលិខិតរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផ្ញើជូននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

[17] សូមមើលឧបសម្ព័ន្ធ ង៖ លិខិតសន្យារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ទៅនឹងការស្នើសុំបន្ថែមរបស់អង្គជំនុំជម្រះ ដូចមានបង្ហាញនៅក្នុងអនុស្សរណៈ E218/7/2 ប៉ុណ្ណោះ។ ទោះជាក្នុងករណីណាក៏ដោយ សារណានេះមិនអាចចាត់ទុកជាសំណើសុំចុងក្រោយ តាមវិធាន ៨០ ស្ទួន (៤) និង (៥) នោះឡើយ។ សំណើសុំចុងក្រោយនឹងត្រូវដាក់ជាសារណាលម្អិតជាងនេះនៅពេលក្រោយ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមរក្សាសិទ្ធិក្នុងការបង្ហាញពីគម្រោងផ្សេងៗនៅក្នុងសំណើសុំសំណងរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១ នាពេលអនាគតទៀត ប្រសិនបើសំណើរទាំងនេះ បំពេញបន្ថែមនូវលក្ខណៈវិនិច្ឆ័យដែលបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង ។

**អាស្រ័យហេតុនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

- សូមអង្គជំនុំជម្រះមេត្តាជ្រាបអំពីគម្រោងខាងលើ ដែលជាគម្រោង ដូចមានចែងនៅក្នុងវិធាន ២៣ ស្ទួនបួន (៣)(ខ) នៃវិធានផ្ទៃក្នុង។
- សូមអង្គជំនុំជម្រះមេត្តាជ្រាបអំពីការបញ្ជាក់ជូនខាងលើ តបទៅនឹងអនុស្សរណៈ E218/7/2 និងប្រកាសថាការបញ្ជាក់ជូននេះមានភាពសមស្រប នៅក្នុងដំណាក់កាលនេះ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | រាជធានីភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | រាជធានីភ្នំពេញ | |